ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...៤០...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យមេគង្គកម្ពុជា

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខណៈ វិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញ លិខិតស្នើសុំ របស់លោក អ៊ិច សេង ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៣
- បានឃើញ យោបល់របស់ក្រសួងអប់រំ យុវជន និង កីឡា

## ស ំ រ េ ច

**មាត្រា ១ :** ទទួលស្គាល់ គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា *"សាកលវិទ្យាល័យមេគង្គកម្ពុជា"*

" CAMBODIAN MEKONG UNIVERSITY " ហៅកាត់ ជាភាសាខ្មែរ "ស.ម.ក" និង ហៅកាត់ជាភាសាអង់គ្លេស " CMU" ។ សាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និង កីឡា និង មានទីតាំងគោល ស្ថិតនៅ អាគារលេខ ៩ បេ ផ្លូវ ២៧១ សង្កាត់ ទឹកថ្លា ខ័ណ្ឌ ឫស្សីកែវ រាជធានី ភ្នំពេញ ។

**មាត្រា ២ :** សាកលវិទ្យាល័យមេគង្គកម្ពុជា ធ្វើការបណ្តុះបណ្តាល :

- ថ្នាក់បរិញ្ញាប័ត្ររង មានរយៈពេលសិក្សា យ៉ាងតិច ២ ឆ្នាំ ត្រូវនឹង ៨០ ក្រេឌីត ជាមធ្យម ។
- ថ្នាក់បរិញ្ញាប័ត្រ មានរយៈពេលសិក្សា យ៉ាងតិច ៤ឆ្នាំ ត្រូវនឹង ១៦០ ក្រេឌីត ជាមធ្យម ។
- ថ្នាក់ម៉ាស្ទ័រ មានរយៈពេលសិក្សា យ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៥៤ ក្រេឌីត ។
- ថ្នាក់បណ្ឌិត សិក្សានិងស្រាវជ្រាវ រយៈពេល យ៉ាងតិច ៣ ឆ្នាំ ។

**មាត្រា ៣ :** សាកលវិទ្យាល័យមេគង្គកម្ពុជា មាន មហាវិទ្យាល័យ :

១. មហាវិទ្យាល័យ សិល្បៈមនុស្សសាស្ត្រ និង ភាសាបរទេស

២. មហាវិទ្យាល័យ វិទ្យាសាស្ត្រសង្គម

៣. មហាវិទ្យាល័យ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា

៤. មហាវិទ្យាល័យ គ្រប់គ្រង និង ទេសចរណ៍

៥. មហាវិទ្យាល័យ នីតិសាស្ត្រ

៦. មហាវិទ្យាល័យ សេដ្ឋកិច្ច ។

នៅក្នុងសាកលវិទ្យាល័យនេះ មានមជ្ឈមណ្ឌលស្រាវជ្រាវមួយ សំរាប់បំរើសេវាសិក្សាស្រាវជ្រាវ និង ការបោះពុម្ព ។ ទៅអនាគត សាកលវិទ្យាល័យនេះ អាចបើកមហាវិទ្យាល័យ ឬ សាខា ឬ ឯកទេស ឬ ថ្នាក់ ឬ ប្រភេទបណ្តុះបណ្តាល ដទៃទៀត ដោយរៀបចំ សំណុំបែបបទ សុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៤ :** សាកលវិទ្យាល័យមេគង្គកម្ពុជា មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យ និង សំរេច លើ គោលនយោបាយ និង ផែនការអភិវឌ្ឍន៍របស់សាកលវិទ្យាល័យ និង មានក្រុមប្រឹក្សាសិក្សាមួយ សំរាប់ពិនិត្យ និង ផ្តល់យោបល់លើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

**មាត្រា ៥ :** ល័ក្ខខ័ណ្ឌទទួលសិស្សអោយចូលរៀន :

- ថ្នាក់បរិញ្ញាប័ត្ររង : បេក្ខជន ត្រូវមានចំណេះដឹងទាបបំផុត បានសិក្សាបញ្ចប់ថ្នាក់ទី ១២ នៃមធ្យមសិក្សាចំណេះទូទៅ ។
- ថ្នាក់បរិញ្ញាប័ត្រ : បេក្ខជនត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាប័ត្រដែលមានតំលៃស្មើ ។
- ថ្នាក់ម៉ាស្ទ័រ : បេក្ខជនត្រូវមានសញ្ញាប័ត្របរិញ្ញា ឬ សញ្ញាប័ត្រដែលមានតំលៃស្មើ ។
- ថ្នាក់បណ្ឌិត : បេក្ខជនត្រូវមានសញ្ញាប័ត្រម៉ាស្ទ័រ ឬ សញ្ញាប័ត្រដែលមានតំលៃស្មើ ។

សាកលវិទ្យាល័យមេគង្គកម្ពុជា ត្រូវគោរព តាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជននិងកីឡាដែលកំនត់អំពី ការជ្រើសរើសនិស្សិត អោយចូលរៀន នៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

**មាត្រា ៦ :** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យមេគង្គកម្ពុជា មានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ។
- ជ្រើសរើសសិស្ស-និស្សិតអោយចូលរៀន និងជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និង បុគ្គលិកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អ នូវការងារនិស្សិត ការងារសិក្សា ការងារបង្រៀន ការងារស្រាវជ្រាវ ការប្រលង និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា អោយបានទៀងទាត់ តាមការកំណត់ ។

**មាត្រា ៧ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យមេគង្គកម្ពុជា និង បានទទួលជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រ តាមកំរិត និង តាមឯកទេស ដែលបានសិក្សា ។ សញ្ញាប័ត្រនេះ ផ្តល់អោយដោយ សាកលវិទ្យាល័យមេគង្គកម្ពុជា ហើយ ត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និង កីឡា ក្នុងករណី សាកលវិទ្យាល័យនេះ បំពេញ និង អនុវត្តបាន តាមគោលការណ៍កំនត់ របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និង សាកលវិទ្យាល័យមេគង្គកម្ពុជា មានភារកិច្ច រៀង ៗ ខ្លួន ដើម្បីអនុវត្ត និង ប្រតិបត្តិតាមអនុក្រឹត្យនេះ ។

**មាត្រា ៩ :** អនុក្រឹត្យនេះ មានប្រសិទ្ធិភាព គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

[illegible] ខែ ឧសភា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
  អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
  សាលាក្រុងភ្នំពេញ
  " ដើម្បីមុខការ "
  ដូចមាត្រា ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ